# លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង របស់ក្រុមប្រឹក្សាយោបល់

# កម្មវិធីរេដបូកកម្ពុជា

## ខែមករា ឆ្នាំ២០១៤

# លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង

ក្រុមការងារប្រឹក្សាយោបល់នៃកម្មវិធីវេដប្លូកកម្ពុជា


**ជំពូកទី១** សារតានៃកម្មវិធីវេដប្លូកកម្ពុជា និងក្រុមប្រឹក្សាយោបល់

**ជំពូកទី២** គោលបំណងនៃក្រុមប្រឹក្សាយោបល់

**ជំពូកទី៣** រចនាសម្ព័ន្ធ និងការគ្រប់គ្រងនៃក្រុមប្រឹក្សាយោបល់

**ជំពូកទី៤** តួនាទីនៃសហប្រធាន និងសមាជិកនៃក្រុមប្រឹក្សាយោបល់

**ជំពូកទី៥** តួនាទីនៃលេខាធិការដ្ឋានវេដប្លូកកម្ពុជានៅក្នុងក្រុមប្រឹក្សាយោបល់

**ជំពូកទី៦** យន្តការនៃការលំហូរព័ត៌មាន និងផែនការអនុវត្តន៍របស់ក្រុម

**ជំពូកទី៧** ការធ្វើវិសោធនកម្មលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង និងការរំលាយនៃក្រុមប្រឹក្សាយោបល់


## ជំពូកទី១

# សាវតានៃកម្មវិធីរេដបូកកម្ពុជា និងក្រុមប្រឹក្សាយោបល់

ផែនទីបង្ហាញផ្លូវ បានពិពណ៌នាអំពីដំណើរការត្រៀមជាស្រេចសម្រាប់រេដបូកនៅកម្ពុជា និងបានព្រាងពីផែនការចូលរួម និងការប្រឹក្សាយោបល់ពីគ្រប់ភាគីអ្នកពាក់ព័ន្ធនឹងបញ្ហារេដបូក។ ផែនការនេះ បានលើកឡើងពីការចូលរួមរបស់គ្រប់ភាគីចូលរួមពាក់ព័ន្ធ និងការប្រឹក្សាយោបល់នៅក្នុងដំណើរការត្រៀមជាស្រេចសម្រាប់រេដបូកកម្ពុជា ជាពិសេសការបញ្ជាក់ពីការបង្កើតក្រុមប្រឹក្សាយោបល់នេះ ដែលមានតំណាងមកពីគ្រប់ភាគីចូលរួមពាក់ព័ន្ធ ដើម្បីផ្តល់ជាវេទិកាតំណាងឲ្យទស្សនៈរបស់គ្រប់ភាគីចូលរួមពាក់ព័ន្ធ និងជួយផ្តល់សំណូមពរ និងសំណើនានា ជូនដល់ក្រុមការងាររេដបូកកម្ពុជា។

ក្រុមប្រឹក្សាយោបល់ ត្រូវបានបង្កើតឡើងនៅក្នុងដំណើរការជ្រើសរើសមួយជាក់លាក់ ដែលមានការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធ និងក្រោមការរៀបចំសិក្ខាសាលាស្តីពី **ការជ្រើសរើសក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដបូកកម្ពុជា** ដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី២៩-៣០ ខែសីហា ឆ្នាំ២០១៣។ ការរៀបចំនេះគឺមានការរៀបចំដោយលេខាធិការដ្ឋាននៃក្រុមការងាររេដបូកកម្ពុជា ដែលរួមមានការសម្របសម្រួលដោយក្រុមគណៈកម្មការសម្របសម្រួលស្ម័គ្រចិត្ត។ អ្នកចូលរួមត្រូវបានអញ្ជើញមកពី ក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរដែនដីខេត្តដែលមានជនជាតិដើមភាគតិចរស់នៅ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិលថ្នាក់ខេត្ត ជនជាតិដើមភាគតិច វិទ្យាស្ថានអប់រំ វិស័យឯកជន បណ្តាញសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ ។

ក្រុមការងារនេះ មានឈ្មោះថា **ក្រុមការងារប្រឹក្សាយោបល់រេដបូក** និងជាភាសាអង់គ្លេសថា REDD+ Consultation Group ដែលហៅកាត់ថា **ស៊ីជី** (CG)។

ក្រុមប្រឹក្សាយោបល់នេះ គឺជាក្រុមការងារស្ម័គ្រចិត្ត មិនរកកម្រៃ មិនពាក់ព័ន្ធនឹងនយោបាយ និងមានសមាជិកដែលតំណាងឲ្យអង្គការ វិទ្យាស្ថាន និងបណ្តាញ ដែលខ្លួនកំពុងបំរើការងារ។ ក្រុមប្រឹក្សាយោបល់នេះ ត្រូវបានបង្កើតឡើងដោយតម្លាភាព និងមានការចូលរួម និងសម្របសម្រួល ដោយក្រុមនៃអង្គការស្ម័គ្រមួយក្រុម ដើម្បីបំរើផលប្រយោជន៍សាធារណៈ ដោយធ្វើការរួមគ្នាដើម្បីផ្តល់ប្រឹក្សាយោបល់ឲ្យក្រុមការងាររេដបូកកម្ពុជា និងជាវេទិកាតំណាងឲ្យទស្សនៈរបស់ភាគីចូលរួមពាក់ព័ន្ធក្នុងមូលដ្ឋាន ជាពិសេសពីសំណាក់សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងក្រុមជនជាតិដើមភាគតិច លើដំណើរការត្រៀមលក្ខណៈសម្រាប់រេដបូកនៅកម្ពុជា។

ថ្ងៃអនាគត ក្រុមប្រឹក្សាយោបល់ នឹងបន្តធ្វើការអនុវត្តន៍លើការលើកកម្ពស់ការយល់ដឹងពីការអនុវត្តនៃកម្មវិធីរេដបូក ដោយមានយន្តការ និងផែនការ។

ក្រុមប្រឹក្សាយោបល់នេះ ត្រូវបានបង្កើតឡើងនៅ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣។

## ជំពូកទី២
## ទស្សនៈវិស័យ និងគោលបំណងនៃក្រុមប្រឹក្សាយោបល់

**គោលបំណង**

ផ្តល់ប្រឹក្សាយោបល់ឲ្យក្រុមការងាររេដបូកកម្ពុជា និងជាវេទិកាតំណាងឲ្យទស្សនៈរបស់ភាគីចូលរួមពាក់ព័ន្ធក្នុងមូលដ្ឋាន ជាពិសេសពីសំណាក់សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន គ្រឹះស្ថានអប់រំ សហគមន៍ និងក្រុមជនជាតិដើមភាគតិច លើដំណើរការត្រៀមលក្ខណៈ និងអនុវត្តន៍ សម្រាប់រេដបូកនៅកម្ពុជា។

## ជំពូកទី៣
## រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោបល់

**សមាជិកភាព**

ក្រុមប្រឹក្សាយោបល់នេះ គឺជាក្រុមដែលមានតំណាងមកពី៩ក្រុម និងមានសមាជិក១៨នាក់៖

១. អង្គការមិនមែនរដ្ឋាភិបាលជាតិ (០២រូប)

២. អង្គការមិនមែនរដ្ឋាភិបាលជាតិអន្តរជាតិ (០២រូប)

៣. អង្គការសង្គមស៊ីវិលថ្នាក់ខេត្ត (០២រូប)

៤. ជនជាតិដើមភាគតិច (០២រូប)

៥. គ្រឹះស្ថានអប់រំ (០២រូប)

៦. វិស័យឯកជន (០២រូប)

៧. បណ្តាញសហគមន៍ព្រៃឈើ (០២រូប)

៨. បណ្តាញសហគមន៍នេសាទ (០២រូប) និង

៩. បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ (០២រូប)។

**សមាជិកក្រុមប្រឹក្សាយោបល់ ត្រូវបានបែកចែកជា៖**




សមាជិកនៃក្រុមប្រឹក្សាយោបល់ គឺតំណាងឲ្យ អង្គការ ស្ថាប័ន បណ្តាញ ឬក្រុមពេញច្បាប់ណាមួយ នៅប្រទេសកម្ពុជា ដែលធ្វើកការងារពាក់ព័ន្ធលើកម្មវិធីរេដបូក និង/ឬ វិស័យព្រៃឈើនៅកម្ពុជា។

ក្រោមការសម្របសម្រួលពីលេខាធិការដ្ឋាន ក្រុមប្រឹក្សាយោបល់ ធ្វើការអនុវត្តទៅតាមគោលដៅ និងគោលបំណងរបស់កម្មវិធីរេដបូក ដោយមានការសម្របសម្រួលពីសហប្រធានក្រុមប្រឹក្សាយោបល់។ ក្រុមប្រឹក្សាយោបល់ ត្រូវធ្វើការជាមួយលេខាធិការដ្ឋាន ដើម្បីធានានូវគុណតម្លៃប្រកបដោយ វិជ្ជាជីវៈ តម្លាភាព និងគណនេយ្យភាពនៅគ្រប់សកម្មភាពទាំងអស់។

ក្រុមប្រឹក្សាយោបល់ និងលេខាធិការដ្ឋានរេដបូក ត្រូវធ្វើការងារជាមួយគ្នាយ៉ាងជិតស្និទ្ធិ ដើម្បីធានានូវទំនាក់ទំនងការងារល្អ និងរក្សានូវការប្រាស្រ័យទាក់ទង ដែលមានស្រាប់ឲ្យមានប្រសិទ្ធភាព រវាងក្រុមប្រឹក្សាយោបល់ លេខាធិការដ្ឋានរេដបូក និងភាគីចូលរួមពាក់ព័ន្ធផ្សេងៗទៀត។ ក្រុមប្រឹក្សាយោបល់ ត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើ គោលបំណង យន្តការ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយទាំងឡាយរបស់ក្រុមប្រឹក្សាយោបល់ ក៏ដូចជារបស់កម្មវិធីរេដបូកកម្ពុជា។

**លក្ខខណ្ឌសម្រាប់សមាជិកនៃក្រុមប្រឹក្សាយោបល់** គឺត្រូវបានបង្កើតឡើងដោយក្រុមគណៈកម្មការស្ម័គ្រចិត្ត (VFC) ដែលត្រូវបានតាក់តែងឡើងដោយមានការពិចារណាទៅតាមកម្រិតយល់ដឹងរបស់ក្រុម នីមួយៗ នៃក្រុមប្រឹក្សាយោបល់។ លក្ខណៈវិនិច្ឆ័យរួមសម្រាប់សមាជិកក្រុមប្រឹក្សាយោបល់ មានដូចខាង ក្រោមនេះៈ

១. តម្រូវការៈ

- សមាជិកនៃក្រុមនេះ ត្រូវតែជាអ្នកតំណាងឲ្យក្រុមណាមួយ
- ត្រូវតែជាអង្គការ ក្រុម ឬ ស្ថាប័នស្របច្បាប់ ដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសកម្ពុជា
- អង្គការ ឬ ស្ថាប័ននោះ ត្រូវតែមានសកម្មភាពពាក់ពន្ធ័ជាមួយនឹងព្រៃឈើនៃប្រទេសកម្ពុជា ឬ វិស័យធនធានធម្មជាតិ គោលនយោបាយយ៉ាងតិច....ឆ្នាំ (អាស្រ័យទៅលើក្រុមនីមួយៗ)

- អ្នកតំណាង ត្រូវមានកំរិតវប្បធម៌យ៉ាងតិចត្រឹម...ដែលពាក់ព័ន្ធ ដូចជា ព្រៃឈើ ជលផល បរិស្ថាន ការប្រែប្រួលអាកាសធាតុ កសិកម្ម និងធនធានធម្មជាតិ ។

- សមាជិកក្រុមពិភាក្សា ត្រូវតែទទួលបានការយល់ព្រមពីអង្គការ ក្រុម ឬ ស្ថាប័នរបស់ខ្លួន ។

**២.គុណសម្បត្តិ៖**

- មានការតាំងចិត្តខ្ពស់ក្នុងការចូលរួមចំណែកក្នុងទំនួលខុសត្រូវរបស់សមាជិកក្រុម

- មានបទពិសោធន៍ធ្វើការជាមួយសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ (CBNRM) ឬ បទពិសោធន៍ទាក់ទងនឹង បណ្ដាញ និងក្រុមការងាររេដបូក)

- មានការទំនាក់ទំនង និងប្រាស្រ័យទាក់ទងល្អ ជំនាញក្នុងសម្របសម្រួល និង អន្តរបុគ្គល

- មានចំនេះដឹង និងមានបទពិសោធន៍ទាក់ទងជាមួយសហគមន៍មូលដ្ឋាន ឬ ជនជាតិដើម ភាគតិច និងយល់ដឹងពីគោលនយោបាយនៅក្នុងប្រទេសកម្ពុជា

- ចេះភាសាខ្មែរ (និងចេះភាសាអង់គ្លេសបានកាន់តែប្រសើរ)

**៣. កំណត់សំគាល់**

- មិនមានការប្រកាន់ក្រុមជាតិសាសន៍ សាសនា ភេទ និងជនពិការ។

*(សូមរកមើលលក្ខណៈវិនិច្ឆ័យនៃក្រុមនីមួយៗនៅក្នុងឧបសម្ព័ន្ធទី១)*

**ការជ្រើសរើសសមាជិកក្រុមប្រឹក្សាយោបល់ និងអណត្តិកាន់តំណែងជាសមាជិក**

- សមាជិកក្រុមប្រឹក្សាយោបល់ ត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគីចូលរួមពាក់ព័ន្ធពេញសិទ្ធិ ដែលតំណាងឲ្យអង្គការ ស្ថាប័ន ឬក្រុមបណ្ដាញណាមួយ (ដែលមាន៩ក្រុម) សម្រាប់ អណត្តិ គឺមានរយៈពេល បី(០៣)ឆ្នាំ ដោយមានសមាជិកត្រូវបានជ្រើសរើសសម្រាប់ក្រុមនីមួយៗចំនួន ពីរ(០២)នាក់។ ការជ្រើសរើសនេះ គឺមានការបន្ត និងជ្រើសរើសជាថ្មីឡើងវិញជាប្រចាំ ទៅតាមរយៈពេលដែលបានកំណត់ និងដោយផ្អែកទៅលើយន្តការដែលបានអនុវត្តស្រាប់ និងអាចបន្តអាណត្តិតាមការសម្រេចរបស់កិច្ចប្រជុំក្រុមការងាររេដបូកកម្ពុជា។
*(សូមរកមើលរបាយការណ៍នៃការជ្រើសរើសក្រុមប្រឹក្សាយោបល់ក្នុងឧបសម្ព័ន្ធទី២)*
- ចំពោះអណត្តិនៃការជ្រើសរើសសមាជិកក្រុមប្រឹក្សាយោបល់ ត្រូវចាប់ផ្ដើមបីឆ្នាំក្រោយនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុម ដើម្បីជំនួស ឬបន្តសមាជិកណាដែលចប់អណត្តិ។

- ការបោះឆ្នោតជ្រើសរើស ត្រូវបានធ្វើឡើងនៅក្នុងសិក្ខាសាលាមួយ ដែលមានភាគីចូលរួមពាក់ព័ន្ធ នៅក្នុងដំណើរការជ្រើសរើស។
- សមាសភាពក្រុមប្រឹក្សាយោបល់ ត្រូវបានបោះឆ្នោតជ្រើសរើស ដោយផ្អែកលើសម្លេងភាគច្រើននៃតំណាងអង្គការ ឬក្រុមបណ្តាញនៃក្រុមប្រឹក្សាយោបល់នីមួយៗ។
- ការដាក់មកជាបេក្ខភាព ត្រូវបានប្រកាសដោយលេខាធិការដ្ឋានរេដបូកកម្ពុជា យ៉ាងហោចណាស់ មួយខែមុនពេលកាលបរិច្ឆេទនៃការបោះឆ្នោត។
- ការដាក់មកជាបេក្ខភាពចំនួនពីររូបពីអង្គការ ឬក្រុមបណ្តាញណាមួយ នឹងមិនត្រូវបានអនុញ្ញាតិឡើយ។ អង្គការ ឬក្រុមបណ្តាញ ដែលបានស្នើនូវបេក្ខភាពលើសពីមួយ គឺប្រធាននៃអង្គការ ឬក្រុមបណ្តាញនោះ នឹងត្រូវបានស្នើសុំឲ្យរើសយកតែមួយក្នុងចំណោមបេក្ខភាពទាំងអស់ដែលបានស្នើឡើង។ អង្គការ ឬក្រុមបណ្តាញនៃក្រុមប្រឹក្សាយោបល់ ដែលមានបុគ្គលិក ឬតំណាងរបស់ខ្លួនមិនទាន់ផុតអណត្តិក្នុងក្រុមប្រឹក្សាយោបល់ នឹងមិនត្រូវបានអនុញ្ញាតិឲ្យស្នើសុំម្តងទៀតនោះទេ។ ស្ត្រីត្រូវបានលើកទឹកចិត្តឲ្យជ្រើសតាំងជាបេក្ខភាព។
- បេក្ខភាពដែលដាក់ពាក្យមក នឹងត្រូវបានបង្កើតជាបញ្ជីឈ្មោះបេក្ខជនទៅតាមក្រុមនីមួយៗ ហើយបេក្ខភាពដែលគ្រប់ និងមិនគ្រប់ទៅនឹងលក្ខខណ្ឌដែលបានតម្រូវ នឹងត្រូវបានជូនដំណឹងពីដំណើរការជ្រើសរើស។ បែបបទសម្រាប់ជ្រើសតាំងបេក្ខភាព ត្រូវបានផ្តល់ជូន និងដែលទម្រង់នេះត្រូវបានតម្រូវឲ្យបំពេញជាដាច់ខាតមុនការជ្រើសរើស។ ដើម្បីឲ្យការជ្រើសមានសុពលភាព ការទទួលយល់ព្រមនូវអ្នកដែលបានជ្រើសតាំងជាបេក្ខភាព ត្រូវបានជូនជាដំណឹង។
- ដំណើការជ្រើសរើសសមាជិកក្រុមប្រឹក្សាយោបល់ នឹងត្រូវធ្វើឡើងជាបីប្រភេទ៖
    ១. ការបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ(online) ដែលការបោះឆ្នោតនេះ នឹងចាប់ផ្តើមធ្វើមួយខែមុន នៃថ្ងៃបោះឆ្នោតចុងក្រោយនៅក្នុងសិក្ខាសាលាជាតិ។
    ២. ការបោះឆ្នោតតាមរយៈប្រអប់សំបុត្រប្រៃណីយ៍ ធ្វើឡើងសម្រាប់បណ្តាញសហគមន៍ព្រៃឈើ បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ និងបណ្តាញសហគមន៍នេសាទ ក្នុងករណីមានបេក្ខជនឈរឈ្មោះលើសពីចំនួន២នាក់។ ដោយឡែក ការជ្រើសរើសសមាជិកក្រុមប្រឹក្សាយោបល់តំណាងជនជាតិដើមភាគតិច ត្រូវដំណើរការជ្រើសរើសតំណាងម្នាក់មកពីខេត្តទាំង១៥ ដែលមានជនជាតិដើមភាគតិចរស់នៅ។
    ៣. ការបោះឆ្នោតសម្រេចចុងក្រោយ នៅក្នុងសិក្ខាសាលាជាតិ ដែលមានភាគីចូលរួមពាក់ព័ន្ធ ក្នុងការបោះឆ្នោត។ ចំពោះអ្នកដែលបានបោះឆ្នោត ជាមួយនឹងមធ្យោយមួយក្នុងចំណោមមធ្យោយបានដែលបានរៀបរាប់ខាងលើ នឹងមិនត្រូវបានអនុញ្ញាតិឲ្យបោះឆ្នោតម្តងទៀតនោះទេ នៅថ្ងៃសិក្ខាសាលានេះ។

- នៅក្នុងសិក្ខាសាលា ជាកន្លែងដែលការបោះឆ្នោតត្រូវបានធ្វើឡើងចុងក្រោយ សន្លឹកឆ្នោតនឹងត្រូវបានចែកជូនចំពោះអ្នកចូលរួម ដែលមានសិទ្ធិក្នុងការបោះឆ្នោត។ មុនពេលសន្លឹកឆ្នោត ត្រូវបានអាន និងរាប់ ហើយអ្នករៀបចំការបោះឆ្នោត ត្រូវធានាថា អង្គការ ឬក្រុមបណ្តាញនីមួយៗ បានធ្វើការបោះឆ្នោតតែមួយសម្លេង។
- អ្នកបោះឆ្នោតត្រូវបានស្នើឲ្យគូសនៅលើឈ្មោះ អ្នកដែលគេចង់បោះ ឆ្នោតឲ្យនៅលើសន្លឹកឆ្នោត។ ដើម្បីឲ្យមានសុពលភាព ចំនួនដែលគូសនៅលើសន្លឹកឆ្នោត មិនត្រូវគូសលើសពីចំនួនពីរនាក់នោះទេ។
- នៅពេលមានសម្លេងឆ្នោតស្មើគ្នា បេក្ខជននឹងត្រូវបានស្នើសុំឲ្យធ្វើការចរចារវាងគ្នា។ ប្រសិនបើការចរចារមិនបានសម្រេច ការជ្រើសរើសដោយលំអៀងទៅលើគុលុ្យភាពយេនឌ័រ។ ប្រសិនបើនៅពេលដែលសន្លឹកឆ្នោតស្មើគ្នាចំពោះបេក្ខជនមានភេទដូចគ្នា ការបោះឆ្នោតនឹងប្រព្រឹត្តម្តងទៀត សម្រាប់បេក្ខជនដែលមានសម្លេងឆ្នោតស្មើគ្នាតែប៉ុណ្ណោះ។
- សមាជិកក្រុមប្រឹក្សាយោបល់ ក៏អាចឈរឈ្មោះសម្រាប់ការបោះឆ្នោតជាអតិបរិមាណ ពីរអណត្តិជាប់គ្នា។
- សមាជិកក្រុមប្រឹក្សាយោបល់ទាំងឡាយណា ដែលចង់លាឈប់ពីមុខតំណែងរបស់ខ្លួន គឺត្រូវជូនដំណឹងជាលាយល័ក្ខអក្សរយ៉ាងហោចណាស់ក៏មួយខែមុន ហើយនឹងត្រូវបានអនុញ្ញាតិឲ្យឈប់ពីតំណែង ដរាបណាតំណែងរបស់ខ្លួនត្រូវបានគេជំនួស។ ការជូនដំណឹង ត្រូវផ្តល់ជូនទៅប្រធានក្រុមប្រឹក្សាយោបល់ ឬ អនុប្រធានក្នុងករណីប្រធានអវត្តមាន ។

## កិច្ចប្រជុំក្រុមប្រឹក្សាយោបល់

ក្រុមប្រឹក្សាយោបល់ អាចមានកិច្ចប្រជុំ បី(០៣) ប្រភេទ៖ **កិច្ចប្រជុំពីរខែម្តង កិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញ**។

- **កិច្ចប្រជុំពីរខែម្តង** គឺត្រូវបានធ្វើឡើង ដើម្បីពិនិត្យទៅលើកិច្ចការងាររបស់ក្រុមការងាររេដបូក ផែនការអនុវត្តន៍ដោយពិភាក្សាទៅលើបញ្ហារួមរបស់ក្រុមប្រឹក្សាយោបល់ ផ្តល់នូវព័ត៌មានថ្មីៗពីសកម្មភាពរបស់សមាជិក ផ្តល់ជាវេទិកាដើម្បីពិភាក្សានូវយុទ្ធសាស្រ្តនិងការអនុវត្តថ្មីៗ និងពិនិត្យមើលទៅលើបញ្ហាបន្ទាន់នៃក្រុម។
  - កិច្ចប្រជុំពីរខែម្តង ត្រូវបានបើកចំហចំពោះសមាជិកទាំងអស់របស់ក្រុមប្រឹក្សាយោបល់។ សមាជិកទាំងឡាយ អាចលើកជាសំណើទៅកាន់ប្រធាន ដើម្បីអញ្ជើញអង្គការ ស្ថាប័ន ឬ អ្នកជំនាញឯករាជ្យ ជាអ្នកសង្កេតការ ឬ ជាវាគ្មិន។

- o ក្នុងករណីដែលត្រូវធ្វើការសម្រេចចិត្តលើបញ្ហា ឬ ការងារណាមួយ សមាជិក ឬ អ្នកតំណាងក្រុមនីមួយៗ អាចអនុញ្ញាតឲ្យបោះឆ្នោតមួយសម្លេង ។
- o សេក្តីជូនដំណឹងអំពីកិច្ចប្រជុំ ត្រូវបានចែកជូនតាមរយៈអ៊ីម៉ែលដោយប្រធានក្រុមប្រឹក្សាយោបល់ (ដែលអាចមានការសម្របសម្រួលពីលេខាធិការដ្ឋានវេជបូក) ជាអប្បបរិមាណមួយ(០១)សប្តាហ៍ ក្នុងអំឡុងថ្ងៃធ្វើការងារ មុនកិច្ចប្រជុំកើតឡើង។
- o សមាជិកក្រុមប្រឹក្សាយោបល់ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរមកប្រធាន ក្នុងរង្វង់ពីរ(០២)ថ្ងៃ កំឡុងថ្ងៃធ្វើការងារ ចំពោះរាល់ការផ្លាស់ប្តូរទាំងឡាយណា ឬ រាល់ការអវត្តមាននៃអ្នកតំណាង ដើម្បីចូលរួមកិច្ចប្រជុំពីរខែម្តងនេះ។
- o ប្រធាន (ដែលអាចមានការជួយពីលេខាធិការដ្ឋានវេជបូក) ត្រូវទទួលខុសត្រូវរាល់ការប្រមូល និងចែកជូននូវកំណត់ហេតុនៃកិច្ចប្រជុំ។
- o រាល់កំណត់ហេតុនៃកិច្ចប្រជុំនីមួយៗ ត្រូវបានចែកជូនដល់សមាជិកទាំងអស់ ក្នុងរង្វង់មួយ(០១) សប្តាហ៍ កំឡុងថ្ងៃធ្វើការងារ មុនពេលសេចក្តីសម្រេចនៃកិច្ចប្រជុំនីមួយៗ។

- **កិច្ចប្រជុំប្រចាំឆ្នាំ** គឺមានគោលបំណងចំបងដើម្បីពិនិត្យទៅលើវឌ្ឍនភាព និងប្រសិទ្ធិភាពនៃដំណើរការនៃការធ្វើការងារ ភាពជោគជ័យ និងភាពប្រឈមនៃក្រុមប្រឹក្សាយោបល់ និងធ្វើការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងលេខាសាជាថ្មី ដែលស្ថិតក្រោមលក្ខខណ្ឌដូចតទៅ៖
  - o ប្រធាន (ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋានវេជបូកកម្ពុជា) ត្រូវជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់នូវកិច្ចប្រជុំប្រចាំឆ្នាំ យ៉ាងហោចណាស់ ៣០ថ្ងៃមុនកិច្ចប្រជុំ ជាមួយនឹងការដាក់ស្នើបញ្ចូលនូវរបៀបវារៈ។
  - o សមាជិករបស់ក្រុមប្រឹក្សាយោបល់ ត្រូវតែមានវត្តមាន ហាសិបភាគរយបូកមួយ (៥០%+១) ដើម្បីបង្កើតចំនួនកូរ៉ុម។
  - o ប្រធាន ត្រូវជូនដំណឹងដល់តំណាងក្រុមនីមួយៗ រៀបចំបង្ហាញពីវឌ្ឍនភាព និងប្រសិទ្ធិភាពនៃដំណើរការនៃការធ្វើការងារ ភាពជោគជ័យ និងភាពប្រឈមនៃក្រុមប្រឹក្សាយោបល់។
  - o សេចក្តីជូនដំណឹង គួររួមបញ្ចូលទាំងការអំពាវនាវឲ្យមានការស្នើបេក្ខភាពសម្រាប់ការបោះឆ្នោតក្នុងមុខតំណែង ប្រធាន អនុប្រធាន និងលេខា។
  - o ការស្នើឡើងនូវបេក្ខជនសម្រាប់តំណែងជាប្រធាន អនុប្រធាន និងលេខា ត្រូវដាក់សំណើទៅកាន់លេខាធិការដ្ឋានវេជបូកកម្ពុជា ក្នុងកំឡុងពេល បី(០៣) សប្តាហ៍ មុនកិច្ចប្រជុំប្រចាំឆ្នាំ។
  - o លេខាធិការដ្ឋានវេជបូកកម្ពុជា ត្រូវចែកជូននូវបញ្ជីចុងក្រោយនៃបេក្ខជនសម្រាប់មុខតំណែងទាំងបីទៅសមាជិកទាំងអស់ មិនឲ្យយឺតជាង ពីរ(០២)សប្តាហ៍ មុនកិច្ចប្រជុំប្រចាំឆ្នាំ។

- **កិច្ចប្រជុំវិសាមញ្ញ** គឺត្រូវបានធ្វើឡើង ដើម្បីដោះស្រាយនូវរាល់បញ្ហាបន្ទាន់ ឬ បញ្ហាសំខាន់ ដែលជះឥទ្ធិពលដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាយោបល់ និង/ឬ កម្មវិធីរេដបូកកម្ពុជា។ កិច្ចប្រជុំវិសាមញ្ញអាចត្រូវបានស្នើឡើងដោយៈ
    - ការដាក់សំណើជាលាយល័ក្ខអក្សររបស់សមាជិកទៅកាន់ ប្រធានក្រុមប្រឹក្សាយោបល់ (ដោយមានការជូនដំណឹងដល់លេខាធិការដ្ឋានរេដបូកកម្ពុជា) យ៉ាងហោចណាស់ក៏ត្រូវមាន ហាសិបបូកមួយ (៥០%+១) នៃសមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់។ កិច្ចប្រជុំត្រូវស្នើឡើងក្នុងកំឡុងមួយសប្តាហ៍ លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះ។
    - ក្នុងករណីមានបញ្ហាបន្ទាន់ ដែលប៉ះពាល់ដល់ការងាររបស់ក្រុមប្រឹក្សាយោបល់ ក្រុមការងាររេដបូក និង/ឬ កម្មវិធីរេដបូកកម្ពុជា និងសមាជិកក្រុមប្រឹក្សារបស់ខ្លួន លេខាធិការដ្ឋាននឹងស្នើឲ្យមានកិច្ចប្រជុំរវាងក្រុមប្រឹក្សាយោបល់។ កិច្ចប្រជុំបន្ថែម អាចត្រូវបានកោះហៅដោយប្រធានក្រុមប្រឹក្សាយោបល់ ឬ សមាជិកក្រុមប្រឹក្សាយោបល់ ដោយសរសេរសំណើជាលាយលក្ខអក្សរជាមុន ទៅប្រធានក្រុមប្រឹក្សាយោបល់។ សេចក្តីជូនដំណឹងស្តីពីការប្រជុំក្រុមប្រឹក្សាយោបល់ គួរត្រូវបានផ្ញើរជូនទៅកាន់សមាជិកនីមួយៗ យ៉ាងហោចណាស់ឲ្យបានដប់ (១០)ថ្ងៃ កំឡុងថ្ងៃធ្វើការងារ មុនកិច្ចប្រជុំ។
    - សមាជិករបស់ក្រុមប្រឹក្សាយោបល់ ត្រូវតែមានវត្តមាន ហាសិបភាគរយបូកមួយ (៥០%+១) ដើម្បីបង្កើតចំនួនកូរ៉ុម។ សេចក្តីសម្រេច នឹងត្រូវបានធ្វើឡើងដោយសម្លេងពីរភាគបី (២/៣) នៃចំនួនអ្នកចូលរួម លើកលែងតែក្នុងករណីពិសេសណាមួយ ដែលមិនមានចែងក្នុងលក្ខន្តិក:នេះ ហើយរាល់សេចក្តីសម្រេចត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាយោបល់នីមួយៗ។
    - ក្រុមប្រឹក្សាយោបល់ អាចស្នើកិច្ចប្រជុំពិសេស (សម្រាប់តែសមាជិកក្រុមប្រឹក្សាយោបល់តែប៉ុណ្ណោះ) ដើម្បីដោះស្រាយបញ្ហាសម្ងាត់។ ក្នុងករណីនេះ មានតែសេចក្តីសម្រេចចុងក្រោយប៉ុណ្ណោះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកំណត់ហេតុ និងធ្វើការចែកជូនសមាជិកនៃក្រុម។

**កូរ៉ុម**

- សម្រាប់កិច្ចប្រជុំពីរខែម្តង និងកិច្ចប្រជុំប្រចាំឆ្នាំ គឺអាចប្រព្រឹត្តទៅបានដោយតម្រូវឲ្យមានការចុះឈ្មោះចូលរួមយ៉ាងតិច ហាសិបភាគរយបូកមួយ (៥០%+១) នៃសមាជិកក្រុមប្រឹក្សាទាំងអស់។

- សម្រាប់កិច្ចប្រជុំវិសាមញ្ញ គឺយ៉ាងហោចណាស់ក៏ត្រូវមានការចុះឈ្មោះចូលរួម ហាសិបភាគរយបូកមួយ (៥០%+១) នៃសមាជិកក្រុមប្រឹក្សាទាំងអស់។
- សេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំនីមួយៗ តម្រូវឲ្យមាន ពីរភាគបី(២/៣) នៃចំនួនសមាជិក ដែលបានចូលរួមសរុបនៃ ហាសិបភាគរយបូកមួយ(៥០%+១) នៃកូរ៉ុម។
- ប្រធាន (ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋានរេដបូកកម្ពុជា) ត្រូវតែជាអ្នករៀបចំអង្គប្រជុំប្រចាំពីរខែម្តង កិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញ ដោយមានសហាដឹកនាំអង្គប្រជុំ (១)ប្រធាននៃក្រុមប្រឹក្សាយោបល់ និង (២)តំណាងនៃលេខាធិការដ្ឋានរេដបូកកម្ពុជា។

## ការសម្របសម្រួលនៃកិច្ចប្រជុំ

ការសម្របសម្រួលនៃកិច្ចប្រជុំ នឹងធ្វើឡើងដោយមានការប្តូរវេនគ្នារវាងសមាជិកក្រុមប្រឹក្សាយោបល់ និងដែលមានសហាប្រធានតំណាង មកពីក្រុមប្រឹក្សាយោបល់ (ប្រធាន) និងតំណាងមកលេខាធិការដ្ឋានរេដបូកកម្ពុជា (ប្រធាន) ដើម្បីបើកកិច្ចប្រជុំ។

## កំណត់ត្រាប្រជុំក្រុមប្រឹក្សាយោបល់

- កំណត់ហេតុពេញលេញរាល់កិច្ចប្រជុំក្រុមប្រឹក្សាយោបល់ទាំងអស់ ត្រូវរក្សាទុកដោយលេខានៃក្រុមប្រឹក្សាយោបល់ និង/ឬ លេខាធិការដ្ឋានរេដបូក។ កំណត់ហេតុ នឹងត្រូវបានចែកជូនទៅសមាជិកទាំងអស់ និងអាចរកមើលបាននៅក្នុងគេហទំព័ររបស់កម្មវិធីរេដបូកកម្ពុជា (www.cambodia-redd.org)។ កំណត់ហេតុទាំងអស់នេះ នឹងត្រូវបានចងក្រងទុកនៅស្នាក់ការកណ្តាលនៃលេខារបស់ក្រុមប្រឹក្សាយោបល់ និង/ឬ លេខាធិការដ្ឋានរេដបូក។ កំណត់ហេតុរាល់កិច្ចប្រជុំនីមួយៗ នឹងត្រូវបានពិនិត្យដោយសមាជិកអង្គប្រជុំ និងអនុម័តចុងក្រោយដោសហាប្រធានទាំងពីរ បន្ទាប់ពីកិច្ចប្រជុំរយៈពេល មួយសប្តាហ៍ (ប្រាំពីរថ្ងៃ)។

## របាយការណ៍ប្រចាំឆ្នាំ

- របាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាយោបល់៖ សមាជិកតំណាងក្រុមនីមួយៗ នឹងត្រូវធ្វើការសង្ខេបព័ត៌មាន និង/ឬ សកម្មភាពរបស់ខ្លួន ហើយផ្ញើជូនប្រធាននៃក្រុមប្រឹក្សាយោបល់ ក្នុងការរៀបចំចងក្រង (ដោយមានការជួយគាំទ្រពីលេខាធិការដ្ឋាន) និងផ្សព្វផ្សាយជាសាធារណៈ ក្នុងឆ្នាំនីមួយៗ។
- របាយការណ៍ប្រចាំឆ្នាំ ត្រូវដាក់បញ្ចូលនូវសេចក្តីសង្ខេបសកម្មភាព និងរបាយការណ៍អនុវត្តន៍ ក៏ដូចជាព័ត៌មានផ្សេងៗទៀត ដែលបានអនុវត្តដោយក្រុមប្រឹក្សាយោបល់។

- របាយការណ៍ប្រចាំឆ្នាំ នឹងត្រូវបានអនុម័តយល់ព្រមពីសមាជិកក្រុមប្រឹក្សាយោបល់ និងចុះហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាយោបល់។

**ការរក្សាកំណត់ត្រារបស់ក្រុមប្រឹក្សាយោបល់**

រាល់កំណត់ត្រាសំខាន់ៗរបស់ក្រុមប្រឹក្សាយោបល់ ត្រូវរក្សាទុកនៅលេខារបស់ក្រុមប្រឹក្សាយោបល់ និង/ឬ លេខាធិការដ្ឋានវេជបូកកម្ពុជា។ ឯកសារសំខាន់ៗរួមមាន៖ ឯកសារបង្កើតក្រុមប្រឹក្សាយោបល់ លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង កំណត់ហេតុប្រជុំ គម្រោងសំណើរបាយការណ៍អនុវត្តន៍ ការងាររបាយការណ៍ប្រចាំឆ្នាំ កិច្ចសន្យា និងឯកសារសំខាន់ៗផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាយោបល់។

## ជំពូកទី៤

## តួនាទីនៃក្រុមប្រឹក្សាយោបល់

ក្រុមប្រឹក្សាយោបល់ ត្រូវបានបែងចែកជាបួនធំៗ រួមមាន៖ ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកនៃក្រុមប្រឹក្សាយោបល់ ដែលមានជូនលម្អិតនៃភារកិច្ចដូចខាងក្រោម៖

**ប្រធាន** (របស់ក្រុមប្រឹក្សាយោបល់)៖

ប្រធានក្រុមប្រឹក្សាយោបល់ ត្រូវចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងអនុវត្តន៍ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមលក្ខន្តិកៈ បេសកកម្ម គោលនយោបាយ និងនីតិវិធី របស់ក្រុមប្រឹក្សាយោបល់ដែលបានចែង។

ប្រធានក្រុមប្រឹក្សាយោបល់ ត្រូវមានអំណាចទូទៅ ដើម្បីពិនិត្យ និងគ្រប់គ្រងទៅលើការងារអនុវត្តរបស់ខ្លួន ដោយគោរពទៅលើការប្រឹក្សា និងមតិយោបល់របស់សមាជិកក្រុម ដែលរួមមាន៖

- ត្រូវតំណាងឲ្យក្រុមប្រឹក្សាយោបល់វេជបូក និងដឹកនាំកិច្ចពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាយោបល់ អ្នកសម្របសម្រួលរបស់លេខាធិការដ្ឋានវេជបូក ឬ ភាគីពាក់ព័ន្ធផ្សេងៗ
- តំណាងឲ្យក្រុមប្រឹក្សាយោបល់ ដែលប្រតិបត្តិការ និងបំរើការងារជូនសមាជិកក្រុម
- ធ្វើការដឹកនាំអង្គប្រជុំទាំងឡាយដែលធ្វើឡើងសម្រាប់ក្រុមប្រឹក្សាយោបល់
- ត្រូវធ្វើជាអធិបតីតំណាងឲ្យក្រុមប្រឹក្សាយោបល់ ដែលបានបង្កើតឡើង
- ប្រធានត្រូវពិចារណា ទទួលយក និងរៀបចំអនុសាសន៍ សម្រាប់ក្រុមប្រឹក្សាយោបល់ ដើម្បីបំពេញនូវរាល់តួនាទី និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សាយោបល់ ដោយមានការឯកភាពពីសមាជិកក្រុម

- សម្របសម្រួល និងពិនិត្យចុងក្រោយទៅលើគោលនយោបាយ នីតិវិធី ផែនការយុទ្ធសាស្រ្ត និងសកម្មភាពអនុវត្តន៍របស់ក្រុមប្រឹក្សាយោបល់ ដែលផ្តល់អនុសាសន៍ និងដាក់ជូនដោយសមាជិកក្រុមនីមួយៗ មុនការដាក់បញ្ជូនទៅលេខាធិការដ្ឋានវេដបូក ដើម្បីដាក់បញ្ជូនបន្តទៅក្រុមការងារវេដបូក
- ធានានូវប្រតិបត្តិការជាទូទៅ ដោយស្របទៅតាមគោលនយោបាយ និងនីតិវិធី របស់សមាជិកក្រុមប្រឹក្សាយោបល់
- ពិនិត្យ និងអនុម័តចុងក្រោយលើរបាយការណ៍វឌ្ឍនភាព របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ទាំងឡាយ ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តរបស់ក្រុមប្រឹក្សាយោបល់។
- ស្ថិតក្រោមកាលៈទេសៈបន្ទូរបន្ថយ (ដោយសង្ស័យពីការអនុវត្តមិនបានត្រឹមត្រូវ ឬ អនុវត្តន៍ខុសពីគោលការណ៍របស់ក្រុមប្រឹក្សាយោបល់) ប្រធានក្រុមប្រឹក្សាយោបល់ ត្រូវទទួលខុសត្រូវ ក្នុងការសិក្សា និងស្វែងរកវិធីសាស្រ្ត (ដោយប្រឹក្សាយោបល់ជាមួយសមាជិកក្រុម) ដើម្បីដោះស្រាយបញ្ហាទាំងអស់ តម្រង់ទិស និងគ្រប់គ្រងដំណើរការទាំងមូលរបស់ក្រុមប្រឹក្សាយោបល់។

អនុប្រធានៈ

- ត្រូវបំពេញរាល់ភារកិច្ច និងការទទួលខុសត្រូវទាំងអស់ របស់ប្រធានក្រុមប្រឹក្សាយោបល់ ក្នុងករណីប្រធានអវត្តមាន
- ចូលរួម និងតំណាងក្នុងកិច្ចប្រជុំទាំងឡាយ ដែលពាក់ព័ន្ធនឹងការអនុវត្ត និងសកម្មភាពរបស់ក្រុមប្រឹក្សាយោបល់
- តាមដាន និងអង្កេតនូវសកម្មភាពនៃការអនុវត្តរបស់សមាជិកក្រុមប្រឹក្សាយោបល់
- ជួយ និងសម្របសម្រួលនូវរាល់ភារកិច្ចដែលប្រធានស្នើសុំ។

លេខាធិការៈ

- ជួយសម្របសម្រួលកិច្ចការងាររបស់ប្រធាន និងអនុប្រធាន ដោយធ្វើការពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាយោបល់ ដើម្បីជួយដល់ការគ្រប់គ្រងដំណើរការរបស់ក្រុមប្រឹក្សាយោបល់ ឲ្យមានភាពប្រសើរ និងទទួលបានជោគជ័យ
- ជួយប្រធានក្រុមប្រឹក្សាយោបល់ក្នុងការរៀបចំ កោះហៅកិច្ចប្រជុំ
- ជួយដល់ការងារទាំងឡាយណាដែលបានស្នើសុំដោយប្រធាន អនុប្រធាន ឬ សមាជិកក្រុមប្រឹក្សាយោបល់ ដើម្បីរក្សាភាពរលូននៅក្នុងការអនុវត្តការងារ និងឲ្យត្រឹមត្រូវ នៅពេលដែលប្រធាន និងអនុប្រធានអវត្តមាន។

**សមាជិកក្រុមប្រឹក្សាយោបល់ (រួមបញ្ចូលទាំងប្រធាន អនុប្រធាន និងលេខា)**

សមាជិកក្រុមប្រឹក្សាយោបល់ ដែលរួមបញ្ចូលទាំងប្រធាន អនុប្រធាន និងលេខាធិការ ផ្តល់ប្រឹក្សាយោបល់ដល់ក្រុមការងាររេដបូកកម្ពុជា ដែលមានលម្អិតដូចខាងក្រោម៖

- ប្រមូល សង្ខេប និងរៀបចំយោបល់ សរសេរព្រាងរបាយការណ៍ និងសំណើសេចក្តីសម្រេចចិត្តទៅលើឯកសារ និងការអនុវត្តរបស់ក្រុមការងាររេដបូកកម្ពុជា ដែលបានមកពីក្រុមនីមួយៗដែលខ្លួនតំណាងឲ្យ
- ចូលរួមព្រាងរបាយការណ៍ និងការទំនាក់ទំនងផ្សេងៗ ជាមួយក្រុមការងាររេដបូក
- ជួបប្រជុំរៀងរាល់ពីរខែម្តង ឬទៅតាមតម្រូវការចាំបាច់ ជាមួយលេខាធិការដ្ឋានរេដបូក ក្រុមការងាររេដបូក និងអង្គការភាគីចូលរួមពាក់ព័ន្ធនានា ដើម្បីពិភាក្សាលើដំណើរការត្រៀមលក្ខណៈសម្រាប់រេដបូកកម្ពុជា
- សម្របសម្រួល និងចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរេដបូកនៅកម្ពុជាទៅដល់ សមាជិកក្រុមប្រឹក្សាយោបល់ ក្រុម(ប្រឹក្សាយោបល់នីមួយៗ)ដែលខ្លួនតំណាងឲ្យក្រុមការងាររេដបូក លេខាធិការដ្ឋានរេដបូក និងសមាជិកភាគីចូលរួមពាក់ព័ន្ធដទៃទៀត
- ផ្តល់យោបល់ ឬសំណើជាលាយលក្ខណ៍អក្សរដល់ក្រុមការងាររេដបូក ស្តីពីបញ្ហាកង្វល់នានាតាងនាមឲ្យក្រុមនីមួយៗដែលខ្លួនតំណាងឲ្យ
- ផ្តល់យោបល់ជាក់លាក់លើបញ្ហាសំខាន់ៗ ដូចជា ការប្រឹក្សាយោបល់ ការចូលរួម ឬការរក្សាសន្តិសុខសង្គម និងបរិស្ថាន ជាដើម
- ធ្វើការពិភាក្សាជាមួយក្រុមតំណាងទាំងអស់នៃសមាជិកក្រុមប្រឹក្សាយោបល់ លើមតិយោបល់ ព័ត៌មាន អនុសាសន៍ និង/ឬសំណើសុំពីក្រុមនីមួយៗ មុនដាក់ជូនទៅក្រុមការងាររេដបូក តាមរយៈ លេខាធិការដ្ឋានរេដបូក ដែលមានអ្នកសម្របសម្រួលជាអ្នកធ្វើដាក់បញ្ជូន។
- ជួបប្រជុំជាប្រចាំ ជាមួយភាគីអ្នកពាក់ព័ន្ធនៃក្រុមនីមួយៗដែលខ្លួនតំណាងឲ្យ ដើម្បីធ្វើការពិភាក្សា និងផ្តល់មតិយោបល់ ជូនត្រលប់មកក្រុមការងាររេដបូកកម្ពុជា
- ចូលរួមជាសមាជិកក្រុមការងារបច្ចេកទេសរេដបូក

  ក្នុងនាមជាតំណាងឲ្យក្រុមប្រឹក្សាយោបល់ ដើម្បីគាំទ្រដល់ការប្រឹក្សាយោបល់ និងសកម្មភាពលើកកម្ពស់ការយល់ដឹង ពីដំណើរការត្រៀមលក្ខណៈសម្រាប់ការអនុវត្តរេដបូកនៅកម្ពុជា។

**អភិបាលកិច្ចដោយសហប្រធានក្រុមប្រឹក្សាយោបល់**

- ក្រុមប្រឹក្សាយោបល់ ត្រូវបានអភិបាលដោយសហប្រធាន ដែលដើរតួជាក្នុងការគ្រប់គ្រងក្រុម។
- ប្រធានក្រុមប្រឹក្សាយោបល់ ដឹកនាំការបង្កើត និងអនុវត្តន៍យន្តការ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយ ដែលធានាឲ្យគោលបំណង និងសកម្មភាពរបស់ក្រុមប្រឹក្សាយោបល់ស្របទិសគ្នា និងចូលរួមចំណែកទៅក្នុងគោលបំណង និងសកម្មភាពអនុវត្តន៍របស់កម្មវិធីរេដបូកកម្ពុជា។

- ប្រធានក្រុមប្រឹក្សាយោបល់ ត្រូវតាមដានការអនុវត្តរបស់ក្រុមប្រឹក្សាយោបល់នីមួយៗ និងការប្រព្រឹត្តរបស់ក្រុម ដើម្បីធានាថាការអនុវត្ត និងលំហូរព័ត៌មានអំពីវេដប្លក មានប្រសិទ្ធិភាព និងប្រសិទ្ធិផល។
- រាល់សកម្មភាព និងការសម្រេចទាំងឡាយ ប្រធានក្រុមប្រឹក្សាយោបល់ ត្រូវធានាឲ្យមានគណនេយ្យភាពចំពោះសមាជិករបស់ខ្លួន និងភាគីចូលរួមពាក់ព័ន្ធទាំងឡាយ។

## ការវាយតម្លៃសមាជិកក្រុមប្រឹក្សាយោបល់

- ការវាយតម្លៃ គឺជាវិធីមួយដើម្បីពិនិត្យទៅលើក្រុមប្រឹក្សាយោបល់ ទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យនៃការអនុវត្ត ដែលមានចែងនៅក្នុងលក្ខខណ្ឌការងារ ដើម្បីធ្វើឲ្យច្បាស់លាស់ថាសមាជិកក្រុមប្រឹក្សាយោបល់នីមួយៗ គឺបំពេញទៅតាមតម្រូវការដែលបានចែង និងផ្តល់ដល់ពួកគាត់នូវការគាំទ្រ និងការអភិវឌ្ឍ ប្រសិនបើពួកគាត់មិនបានបំពេញឲ្យគ្រប់លក្ខខណ្ឌទេនោះ។ ការវាយតម្លៃ ត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។ សមាជិកក្រុមប្រឹក្សាយោបល់ គឺអនុវត្តន៍ភារកិច្ចនៅលើមូលដ្ឋានស្ម័គ្រចិត្ត។ ដូច្នេះ ទម្រង់បែបបទនេះ ត្រូវធ្វើឲ្យបានទាន់ពេល និងមិនស្មុគស្មាញ។
- ប្រធានក្រុមប្រឹក្សាយោបល់ នឹងជួយសម្របសម្រួលធ្វើការវាយតម្លៃប្រចាំឆ្នាំ លើការបំពេញការងាររបស់សមាជិកក្រុមប្រឹក្សាយោបល់នីមួយៗដែលស្ម័គ្រចិត្ត ដោយផ្អែកតាមគោលបំណងនៃការបំពេញ ការងារ ដែលបានព្រមព្រៀង។

*(សូមរកមើលទម្រង់បែបបទនៃការវាយតម្លៃក្រុមប្រឹក្សាយោបល់នៅក្នុងឧបសម្ព័ន្ធទី៣)*

## ការចូលរួមរបស់សមាជិកក្រុមប្រឹក្សាយោបល់

- សមាជិកណាមួយដែលអវត្តមានលើសពីបួនដងបន្តបន្ទាប់គ្នា និងមិនបានផ្តល់មតិយោបល់ពីក្រុមរបស់ខ្លួនដល់ប្រឹក្សាយោបល់ក្នុងកិច្ចសមាជិកប្រឹក្សាយោបល់ផ្សេងទៀត អាចធ្វើការស្នើឡើងជាលាយលក្ខអក្សរ ឬ ក្នុងកិច្ចប្រជុំ ដើម្បីពិនិត្យទៅលើសមាជិកភាពរបស់សមាជិកនោះ។
- ប្រធានក្រុមប្រឹក្សាយោបល់ ដឹកនាំការពិភាក្សាលើការជ្រើសរើស តែងតាំង ព្យួរ ឬដក សមាជិកនៃក្រុមប្រឹក្សាយោបល់ ទៅតាមនីតិវិធីដែលបានចែង ដោយគោរពទៅលើការប្រឹក្សា និងមតិយោបល់ជាមួយសមាជិកក្រុម។

## ជំពូកទី៥
## តួនាទីនៃលេខាធិការដ្ឋានរេដបូកកម្ពុជានៅក្នុងក្រុមប្រឹក្សាយោបល់

លេខាធិការដ្ឋានរេដបូកកម្ពុជា៖

- លេខាធិការដ្ឋានរេដបូកកម្ពុជា មានតួនាទីចាំបាច់ក្នុងការបញ្ជូននូវរាល់មតិយោបល់ និងឯកសារទាំងឡាយដែលបានដាក់ជូនមកពីក្រុមប្រឹក្សាយោបល់ ទៅកាន់ក្រុមការងាររេដបូកកម្ពុជាដើម្បីឆ្លើយតបចំពោះសំណើទាំងឡាយឲ្យទាន់ពេលវេលា
- ដោយមានការពិគ្រោះយោបល់ជាមួយប្រធាន ជួយសម្របសម្រួលក្រុមប្រឹក្សាយោបល់ក្នុងការរៀបចំនូវរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ ហើយត្រូវធានាថារាល់ឯកសារសំខាន់ៗ ត្រូវបានផ្តល់ជូនទៅក្រុមប្រឹក្សាយោបល់ សម្រាប់ពិនិត្យឲ្យបានយ៉ាងហោចណាស់មួយសប្តាហ៍(០៧ថ្ងៃ) មុនកិច្ចប្រជុំក្រុមប្រឹក្សាយោបល់
- ជួយសម្របសម្រួល និងរៀបចំរាល់កិច្ចប្រជុំ របាយការណ៍ និងឯកសារពិភាក្សាសម្រាប់ប្រជុំក្រុមប្រឹក្សាយោបល់
- ជួយសម្របសម្រួលលើការងារទាំងឡាយ ដោយមានការអនុម័ត និងយល់ព្រមពីក្រុមប្រឹក្សាយោបល់ ដែលមានសហប្រធានជាអ្នកធ្វើសេចក្តីសម្រេចចិត្ត។
- ចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាប្រឹក្សាយោបល់ ដើម្បីជាមធ្យោបាយចងភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាយោបល់ និងក្រុមការងាររេដបូក។
- ត្រូវធ្វើបច្ចុប្បន្នភាពនៃវឌ្ឍនភាពក្រុមការងាររេដបូកកទៅក្រុមប្រឹក្សាយោបល់ និងត្រលប់ទៅក្រុមការងាររេដបូក។

## ជំពូកទី៦
## យន្តការនៃការលំហូរព័ត៌មាន និងផែនការអនុវត្តន៍របស់ក្រុម

ការទំនាក់ទំនងគឺអាចធ្វើឡើងតាមរយៈមធ្យោបាយផ្សេងៗ៖

- កិច្ចពិភាក្សា ឬ កិច្ចប្រជុំ
- ការផ្ញើសារអេឡិចត្រូនិច ឬ តាមសំបុត្រ
- ការទូរស័ព្ទទំនាក់ទំនង
- គេហទំព័រ (កម្មវិធីរេដបូកកម្ពុជា)

*(សូមរកមើលផែនការយន្តការ និងកាលវិភាគ/តារាងនៃដំណើការប្រមូលនិងផ្តល់ឯកសារសម្រាប់កិច្ចប្រជុំ ក្នុងឧបសម្ព័ន្ធទី.....)*

## ជំពូកទី៧

## វិសោធនកម្មលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង និងការរំលាយនៃក្រុមប្រឹក្សាយោបល់

**វិសោធនកម្មលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង៖**

- លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាយោបល់ អាចធ្វើវិសោធនកម្មផ្លាស់ប្តូរ ឬកែតម្រូវ គ្រប់ពេលវេលា ដោយមានសំណើជាមុនពីសមាជិកភាពនៃក្រុមប្រឹក្សាយោបល់ និងដោយមានការយល់ព្រមអនុម័តពីសហប្រធាននៃក្រុមនេះ។ ការផ្លាស់ប្តូរអាចធ្វើទៅបាន ដរាបមានការយល់ព្រមពី ពីរភាគបី (២/៣) នៃសមាជិកក្រុមប្រឹក្សាយោបល់ក្នុងកិច្ចប្រជុំដែលបានរៀបចំឡើងក្នុងគោលបំណងនេះ។
- ក្រុមប្រឹក្សាយោបល់ ត្រូវគាំទ្រទៅលើដំណោះស្រាយនៃការធ្វើវិសោធនកម្ម ផ្លាស់ប្តូរ និងកែតម្រូវលើលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ដែលស្នើសុំឡើងនេះ។
- ដើម្បីឲ្យការស្នើសុំនោះត្រូវបានពិចារណា និងចាត់វិធានការទាន់ពេលវេលា គឺថាសមាជិកក្រុមប្រឹក្សាយោបល់ ត្រូវប្រមូលមតិយោបល់ ឬ ការសរសេរជាលាយលក្ខណ៍អក្សរនៃការស្នើសុំធ្វើកែប្រែណាមួយនោះ ដោយដាក់ជូនទៅសហប្រធាននៃក្រុមប្រឹក្សាយោបល់ ពិនិត្យ និងចែកជូនដល់សមាជិកក្រុមប្រឹក្សាយោបល់ដទៃទៀតជាដំណឹងយ៉ាងតិច ១០ថ្ងៃ មុនកិច្ចប្រជុំត្រូវបានរៀបចំឡើង។

**ការបញ្ចប់សមាជិកភាព៖**

សមាជិកភាពអាចត្រូវបានបញ្ចប់ស្ថិតក្រោមកាលៈទេសៈដូចតទៅ៖

- ការសុំលាលែង
- ការបញ្ឈប់

*(សូមរកមើលទម្រង់បែបបទនៃការដេកសមាជិកភាព នៅក្នុងឧបសម្ព័ន្ធទី៨)*

**ការបញ្ចប់នូវសមាជិកក្រុមប្រឹក្សាយោបល់៖**

- ប្រធានសមាជិកក្រុមប្រឹក្សាយោបល់ អាចត្រូវបានបញ្ឈប់សមាជិកភាពក្នុងកាលៈទេសៈដូចតទៅនេះ៖
    - ប្រសិនបើគាត់អវត្តមានក្នុងកិច្ចប្រជុំច្រើនដងជាប់ៗគ្នា ហើយមិនបានបញ្ជូនអ្នកតំណាងមកចូលរួមជំនួស។
    - ប្រសិនជាសមាជិកក្រុមប្រឹក្សាយោបល់ គឺនៅក្នុងស្ថានភាពនៃទំនាស់ផលប្រយោជន៍ ដែលមិនអាចដោះស្រាយបាន។
    - ប្រសិនបើសមាជិកក្រុមប្រឹក្សាយោបល់ មិនធ្វើជាតំណាងឲ្យក្រុមរបស់ខ្លួន និងធ្វើឲ្យប៉ះពាល់ជាអវិជ្ជមាននូវរូបភាព ឬ ជំហរជាសាធារណៈរបស់ក្រុមប្រឹក្សាយោបល់ និងកម្មវិធីរេដបូក ឬ ត្រូវបានចាត់ទុកថាធ្វើផ្ទុយទៅនឹងផលប្រយោជន៍របស់ក្រុមប្រឹក្សាយោបល់ និងកម្មវិធីរេដបូក។

- ការបញ្ឈប់មុខតំណែងប្រធាន និង/ឬ សមាជិកក្រុមប្រឹក្សាយោបល់ តម្រូវឲ្យមានសម្លេងយល់ព្រម ហាសិបបូកមួយ (៥០+១) នៃសមាជិកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ។
- ការដាក់ជំនួសសមាជិកក្រុមប្រឹក្សាយោបល់ គួរត្រូវបានបោះឆ្នោតដោយសម្លេង ហាសិបបូកមួយ (៥០+១) របស់សមាជិក។

**ការរំលាយក្រុមប្រឹក្សាយោបល់៖**

- ប្រសិនជាកាលៈទេសៈចាំបាច់តម្រូវឲ្យរំលាយក្រុមប្រឹក្សាយោបល់ ក្រុមប្រឹក្សាយោបល់ត្រូវរំលាយដោយសេចក្តីសម្រេចអនុម័តនៅក្នុងកិច្ចប្រជុំពិសេស ដែលរៀបចំឡើងសម្រាប់ពិភាក្សាលើគោលបំណងនេះ។ ការរំលាយក្រុមប្រឹក្សាយោបល់ អាចធ្វើទៅបានដោយមានសម្លេងគាំទ្រ ហាសិបបូកមួយ (៥០+១) នៃសមាជិកក្រុមប្រឹក្សាយោបល់ និងដោយមានការយល់ព្រមពីក្រុមរបស់ខ្លួននីមួយៗ។
- សេចក្តីជូនដំណឹងនៃកិច្ចប្រជុំពិសេសនៅក្នុង គោលបំណងនៃការរំលាយក្រុមប្រឹក្សាយោបល់នេះ ត្រូវចែកជូនដល់សមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់ ដោយភ្ជាប់ជាមួយនូវមូលហេតុនៃការរំលាយយ៉ាងហោចណាស់ឲ្យបានមុនរយៈពេល ម្ភៃ(២០)ថ្ងៃ នៃមុនកិច្ចប្រជុំ។ ក្នុងរយៈពេលនេះ សមាជិកក្រុមប្រឹក្សាយោបល់ នឹងត្រូវធ្វើការពិភាក្សាជាមួយក្រុមរបស់ខ្លួន ដើម្បីសុំការយល់ព្រមទៅលើការរំលាយនេះ។
- ការរំលាយនេះ នឹងអាចធ្វើឡើងដោយក្រុមប្រឹក្សាយោបល់តែប៉ុណ្ណោះ។

លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានបង្កើតឡើង និងសម្រេចឲ្យប្រើប្រាស់ នៅថ្ងៃទី..... ខែ..... ឆ្នាំ២០១៤ ហើយបានចុះហត្ថលេខាយល់ព្រម ដោយសហប្រធាននៃក្រុមប្រឹក្សាយោបល់ សម្រាប់កម្មវិធីវេជបូកកម្ពុជា។

_______________________ _______________________

**លោក សៀក សុផាត**
សហប្រធានក្រុមប្រឹក្សាយោបល់
តំណាងក្រុមប្រឹក្សាយោបល់នៃក្រុមវិទ្យាស្ថានអប់រំ
សកលវិទ្យាល័យភូមិន្ទភ្នំពេញ

**លោក យុន វឌ្ឍនា**
សហប្រធានក្រុមប្រឹក្សាយោបល់
ប្រធានលេខាធិការដ្ឋានវេជបូកកម្ពុជា
កម្មវិធីវេជបូកកម្ពុជា